# អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

## សេចក្តីសម្រេចកែសម្រួលលើកទី១
## លើឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ សម្រាប់លោក កែវ ចំរើន ធ្វើសេវាកម្មអគ្គិសនី នៅឃុំកញ្ច្រៀច ឃុំត្នោត ឃុំថ្មពូន និងឃុំគោកគង់លិច ស្រុកកញ្ច្រៀច ខេត្តព្រៃវែង

## សម្រាប់ការពង្រីកតំបន់ចែកចាយ

## DECISION ON THE FIRST REVISION OF THE LICENSE DOCUMENT No. 208 LD DATED MARCH 28, 2007 FOR MR. KEO CHÂM REUN FOR PROVIDING ELECTRIC POWER GENERATION AND DISTRIBUTION SREVICES AT KHUM KANH CHREACH, KHUM TNOUT, KHUM THMAR POUN AND KHUM KOUKKONGLECH, KANH CHREACH DISTRICT, PREY VENG PROVINCE.

## FOR EXTENDING DISTRIBUTION AREA

ថ្ងៃទី ខែ ឆ្នាំ២០០៩

, 2009

**ព្រះរាជាណាចក្រកម្ពុជា**

KINGDOM OF CAMBODIA

**ជាតិ សាសនា ព្រះមហាក្សត្រ**

NATION RELIGION KING

**អាជ្ញាធរអគ្គិសនីកម្ពុជា**

ELECTRICITY AUTHORITY OF CAMBODIA

លេខ : -០៩-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី១
# លើឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨
# សម្រាប់លោក កែវ ចំរើន

## DECISION ON THE FIRST REVISION

## OF THE LICENSE DOCUMENT No. 208 LD DATED MARCH 28, 2008 FOR MR. KEO CHÂM REUN

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣០ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 30 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 02 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ២០៨ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក កែវ ចំរើន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨

-Refer to the Consolidated License N0. 208 LD for Mr. Keo Châm Reun issued by Electricity Authority of Cambodia on March 28, 2008.

-យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក កែវ ចំរើន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩

-Refer to the requested letter of Mr. Keo Châm Reun for extending distribution area dated July 14, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០០៩ ដល់ថ្ងៃទី ខែ ឆ្នាំ២០០៩

-In accordance with the consultation with concerned parties and public made from , 2009 to , 2009.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី នៅថ្ងៃទី ខែ ឆ្នាំ២០០៩

-In accordance with the decision of Electricity Authority of Cambodia's Session No. dated , 2009.

# សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០០៨ ដែលបានផ្តល់ជូនលោក កែវ ចំរើន (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំកញ្ជ្រៀច ឃុំត្នោត ឃុំថ្មពូន និងគោកគង់លិច ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ (ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ កែសម្រួលថ្មី) ។ | **Article 1**<br>To revise the license document No. 208 LD dated March 28, 2008 granted to **Mr. Keo Châm Reun** (herein after referred to as "Licensee"), by adding more distribution areas to its existing areas of supply the electric power services at Khum Kanh Chreach, Khum Tnout, Khum Thmar Poun and Khum Koukkonglech, Kanh Chreach District, Prey Veng Province. (As shown in the attached map in new revised Schedule 1). |
| **ប្រការ ២**<br>ឧបសម្ព័ន្ធទី១ ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 1 of the license document No. 208 LD is replaced by the new revised schedule 1 attached here with. |
| **ប្រការ ៣**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 3**<br>The other contents and conditions of the license document No. 208 LD shall remain unaltered and in force. |
| **ប្រការ ៤**<br>សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ។ | **Article 4**<br>This decision and the attached Schedule are the part of license document No. 208 LD. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ២០៨ ឯអ ដែលតម្កល់ទុក មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 208 LD has been deposited in order that the deposited license document No.208 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០០៩

Phnom Penh, , 2009

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី១

## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## លើកទី នាថ្ងៃទី ខែ ឆ្នាំ២០០៩

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMMENDED IN SESSION OF EAC No. DATED , 2009

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្តល់សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនីនៅឃុំកញ្ជ្រៀច ឃុំត្នោត ឃុំថ្មពូន និងគោកគង់លិច ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។ | 1. The authorizes distribution Areas, where licensee has the right to provide the electricity distribution and supply services is Khum Kanh Chreach, Khum Tnout, Khum Thmar Poun and Khum Koukkonglech, Kanh Chreach District, Prey Veng Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ “ផែនទីកំណត់ព្រំប្រទល់ លេខ 208LD Map-Keo Châm Reun-Revision-1-2009” ។ | 2. The authorized distribution area is determined by “the boundary map No. 208LD Map-Keo Châm Reun-Revision-1-2009”. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំកំណត់ឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យពង្រីកតំបន់ចែកចាយនោះ ។ | 3. Under this license, if licensee intends to request the extension or the additional distribution areas then licensee shall prepare all necessary documents and submit to EAC in accordance with the EAC’s determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |